Washington State Department of Social & Health Services — Transforming lives

CHILD CARE SUBSIDY PROGRAMS (CCSP)

# លិខិតភាពមានសិទ្ធិទទួលបាន **CCSP**

## CCSP Eligibility Letter

| លេខទំនាក់ទំនងសេវាកម្មអតិថិជន | លេខទំនាក់ទំនងសេវាកម្មអតិថិជន |
|---|---|
| លេខសម្គាល់អតិថិជន | កាលបរិច្ឆេទ |

☐ ការថែទាំកុមារតាមរដូវកាល

☐ ការតភ្ជាប់ការងារការថែទាំកុមារ

អ្នកមានសិទ្ធិទទួលបានការថែទាំកុមារជាមួយសហបង់ប្រាក់ប្រចាំខែដែលចាប់ផ្ដើម ______________________ និងបញ្ចប់ ______________________។

បើទាំងប្រអប់មួយ ឬពីរត្រូវបានគូសខាងក្រោម ព័ត៌មានបន្ថែមត្រូវការពីអ្នក ៖

1. ☐ ពួកយើងកំពុងយល់ស្របពាក្យសុំរបស់អ្នក ដែលអ្នកអាចបញ្ចប់ដំណើរការពាក្យសុំ TANF / Workfirst ។ បើអ្នកមិនស្ថិតក្នុងសកម្មភាពយល់ស្របក្នុងរយៈពេល **14** ថ្ងៃ ផលប្រយោជន៍របស់អ្នកនឹងត្រូវបានលុបចោលនៅ ______________________________________។
**WAC 110-15-0020** និង **WAC 110-15-0110**។

2. ☐ ពួកយើងបានកំណត់ភាពមានសិទ្ធិទទួល និងសហទូទាត់ថ្លៃរបស់អ្នកដោយផ្អែកលើឯកសារនៃថ្លៃឈ្នួលដែលរំពឹងទុក និងពេលវេលាការងាររបស់អ្នក ។ ក្នុងរយៈពេល **60** ថ្ងៃ នៃសេចក្ដីប្រកាសនេះ អ្នកត្រូវតែបញ្ជាក់ប្រាក់ចំណូលពិតប្រាកដរបស់អ្នក ឬផលប្រយោជន៍របស់អ្នកនឹងត្រូវបានលុបចោលនៅ ______________________។
**WAC 110-15-0012, 110-15-0065** និង **110-15-0110**។

ឧទាហរណ៍ការបញ្ជាក់រួមមាន ៖ កន្ទុយបង្កាន់ដៃ ប្រវត្តិប្រាក់ខែពីនិយោជករបស់អ្នក ឬការសរសេរជាលាយលក្ខណ៍អក្សរពីនិយោជករបស់អ្នកដែលរាយពីប្រាក់ចំណូលដុលពិតប្រាកដដែលបានទទួលតាំងពីអ្នកបានចូលធ្វើការ ។ ពួកយើងក៏បានភ្ជាប់បែបបទបញ្ជាក់ការងារដែលនិយោជករបស់អ្នកអាចបំពេញបាន ។ សហទូទាត់ថ្លៃរបស់អ្នកនឹងត្រូវបានគណនាឡើងវិញនៅពេលអ្នកផ្គត់ផ្គង់ការផ្ទៀងផ្ទាត់។ ប្រាក់ចំណូលរបស់អ្នកនឹងត្រូវបានកំណត់ឡើងវិញ ហើយបើប្រាក់ចំណូលជាក់ស្ដែងរបស់អ្នកគឺខុសគ្នាពីអ្វីដែលអ្នកបានរាយការណ៍នៅពេលអ្នកបានដាក់ពាក្យ សហទូទាត់ថ្លៃរបស់អ្នកអាចត្រូវបានលៃតម្រូវត្រលប់វិញទៅកាន់កាលបរិច្ឆេទដំបូងនៃភាពមានសិទ្ធិទទួលជំនួយទ្រទ្រង់។ **WAC 110-15-0085**។

សូមផ្ដល់ព័ត៌មានដូចខាងក្រោម ដែលពួកយើងអាចផ្ដល់សិទ្ធិបង់ប្រាក់ដល់អ្នកផ្ដល់សេវាកម្មថែទាំកូនរបស់អ្នក ៖

☐ កាលកំណត់សកម្មភាពដែលបានយល់ស្របរបស់អ្នក ។ ☐ ព័ត៌មានអ្នកផ្ដល់សេវាកម្មរបស់អ្នក ។

បើគ្មានប្រអប់ណាមួយខាងលើត្រូវបានគូសទេ មិនមានព័ត៌មានបន្ថែមដែលត្រូវការទេ ។ អ្នកនឹងទទួលលិខិតជាមួយព័ត៌មានបន្ថែមពេលដែលការបង់ប្រាក់ដល់អ្នកផ្ដល់សេវាកម្មរបស់អ្នកត្រូវបានផ្ដល់សិទ្ធិ ។

<u>សកម្មភាពដែលបានយល់ស្រប</u>

ការថែទាំកុមារត្រូវបានយល់ស្របសម្រាប់ សម្រាប់ចំណុចដូចខាងក្រោម ៖

☐ ការងារ ☐ សកម្មភាព WorkFirst ដែលបានយល់ស្រប ☐ សាលារៀន ☐ ផ្សេងៗ ៖ ______________________________

☐ ការងារ និងការបណ្ដុះបណ្ដាលអាហារមូលដ្ឋាន (BFET) / ធនធានដើម្បីផ្ដួចផ្ដើមការងារដែលមានភាពជោគជ័យ (RISE)

ការថែទាំកុមារកំពុងត្រូវបានយល់ស្របសម្រាប់ សម្រាប់ចំណុចដូចខាងក្រោម ៖

☐ ការងារ ☐ សកម្មភាព WorkFirst ដែលបានយល់ស្រប ☐ សាលារៀន ☐ ផ្សេងៗ ៖ ______________________________

☐ ការងារ និងការបណ្ដុះបណ្ដាលអាហារមូលដ្ឋាន (BFET) / ធនធានដើម្បីផ្ដួចផ្ដើមការងារដែលមានភាពជោគជ័យ (RISE)

<u>សហបង់ប្រាក់</u>

សហបង់ប្រាក់គឺជាចំណែករបស់អ្នកលើការចំណាយការថែទាំកូនរបស់អ្នក និងត្រូវតែត្រូវបានបង់ប្រាក់ដោយផ្ទាល់ទៅអ្នកផ្ដល់សេវាកម្មរបស់អ្នក ។ សហបង់ប្រាក់របស់អ្នកត្រូវបានផ្អែកលើទំហំគ្រួសាររបស់អ្នក និងប្រាក់ចំណូលប្រចាំខែរបស់អ្នក ។

☐ សហបង់ប្រាក់ប្រចាំខែរបស់អ្នកនឹងត្រូវជា $15.00 ពី ដល់ ។

☐ សហបង់ប្រាក់ប្រចាំខែរបស់អ្នកនឹងត្រូវជា $ ពី ដល់ ។

អ្នកត្រូវតែរាយការណ៍ក្នុងរយៈពេល **10** ថ្ងៃ បើប្រាក់ចំណូលប្រចាំខែរបស់គ្រួសារអ្នកលើសពី **$** ឬធនធានលើសពី **$1,000,000.00** ។ **WAC 110-15-0031**

1. ទំហំគ្រួសារ
2. ប្រាក់ចំណូលដុលដែលរកបាន (មុនកាត់ពន្ធ) $ ____________
3. ប្រាក់ចំណូលធ្វើការឲ្យខ្លួនឯង (ក្រោយពីការកាត់បន្ថយដែលអាចអនុគ្រោះពន្ធ) $ ____________
4. ប្រាក់ចំណូលដែលមិនបានរកស៊ី (SSI, SSA, បានទទួលជំនួយកុមារ ការទូទាត់សរុប) $ ____________
5. ប្រាក់ចំណូលសរុប (បូកជួរ 2 ដល់ 4 ខាងលើ) $ ____________
6. តុលាការបានបង្គាប់បញ្ជាឲ្យបង់ជំនួយកុមារ $ ____________
7. កំណត់ប្រាក់ចំណូលដែលអាចរាប់បាន (ដកជួរ 6 ពីជួរ 5) $ ____________
   (ប្រាក់ចំណូលដែលអាចរាប់បានត្រូវបានប្រើដើម្បីកំណត់ភាពមានសិទ្ធិទទួលបាន និងសហបង់ប្រាក់)
8. សហបង់ប្រាក់ត្រូវបានគណនាដូចខាងក្រោម ៖

| ប្រាក់ចំណូលដែលអាចរាប់បាន | សហបង់ប្រាក់ប្រចាំខែ |
|---|---|
| នៅ ឬក្រោម 82% នៃកម្រិតត្រីក្រសហព័ន្ធ (FPL) | $15 |
| លើ 82% និងឡើងដល់ 137.5% នៃ FPL | $65 |
| លើសពី 137.5% និងឡើងដល់ 220% នៃ FPL សូមមើល ៖ ព័ត៌មានជំនួយ និងជំនួយទ្រទ្រង់ការថែទាំកុមារថ្នាក់រដ្ឋ \| DEL | |

ព័ត៌មានខាងការលូតលាស់របស់កុមារ

អ្នកអាចស្វែងយល់ថាតើការអភិវឌ្ឍទារក ឬកូនរបស់អ្នកស្ថិតក្នុងការតាមដាន ឬថាតើទាងត្រូវការការអនុវត្តបន្ថែមបន្តិចទៀតដើម្បីត្រៀមខ្លួនចូលរៀន។ ដើម្បីធ្វើដូច្នេះ អ្នកអាចបំពេញកម្រងសំណួរតាមដានការអភិវឌ្ឍអនុវត្តរបស់កុមារឥតគិតថ្លៃដោយទូរស័ព្ទទៅខ្សែបណ្ដាញទាន់ហេតុការណ៍សុខភាពគ្រួសារ តាមលេខ 1-800-322-2588 ឬចូលទៅកាន់គេហទំព័រជំនួយមាតាបិតា 123 នៅ http://www.parenthelp123.org/child-development/help-me-grow-washington ដើម្បីស្វែងយល់បន្ថែមអំពីវា។

ការយល់ដឹងពីការថែទាំកុមារ (Child Care Aware) ផ្ដល់ជូនព័ត៌មានឥតគិតថ្លៃ មិនលំអៀង និងសេចក្ដីយោងសម្រាប់ក្រុមគ្រួសារដែលស្វែងរកការថែទាំមានគុណភាពខ្ពស់ដែលមានអាជ្ញាប័ណ្ណ។ ទូរស័ព្ទទៅលេខ 1-800-446-1114 ឬលើបណ្ដាញទៅ http://wa.childcareaware.org។

អ្នកអាចស្វែងរកស្ថានភាពត្រួតពិនិត្យសារតាថែទាំកុមារដែលមានអាជ្ញាប័ណ្ណ ប្រវត្តិចេញអាជ្ញាប័ណ្ណ របាយការណ៍តាមដាន ភាសាដែលបាននិយាយ និងច្រើនទៀតនៅការយល់ដឹងពីការថែទាំកុមារ (Child Care Aware) នៅ www.del.wa.gov/check។

កុមារមានសិទ្ធិមនុស្សមូលដ្ឋានដើម្បីឱ្យមានសុវត្ថិភាព។ ការរំលោភបំពាន និងការមិនយកចិត្តទុកដាក់គំរាមកំហែងដល់សុវត្ថិភាពរបស់កុមារដោយដាក់ពួកគេក្នុងហានិភ័យរបួសរាយកាយ ខាងអារម្មណ៍ និងសូម្បីតែដល់បាត់បង់ជីវិត។ បើអ្នកសង្ស័យថា កុមារម្នាក់គឺជាជនរងគ្រោះនៃការរំលោភបំពាន ឬការមិនយកចិត្តទុកដាក់ ចូរទូរស័ព្ទឥតគិតថ្លៃទៅ DSHS តាមលេខ 1-866-END-HARM (1-866-363-4276)។

សិទ្ធិស្នើសុំសវនាការ

បើអ្នកមិនយល់ស្របជាមួយការសម្រេចនេះ អ្នកអាចស្នើសុំសវនាការដោយទាក់ទងការិយាល័យនេះ ឬសរសេរទៅការិយាល័យសវនាការរដ្ឋបាល Office of Administrative Hearings, P.O. Box 42489, Olympia, WA 98504-2489 ។ អ្នកត្រូវតែស្នើសុំសវនាការរបស់អ្នក ៖

- នៅ ឬមុនថ្ងៃមានសុពលភាពនៃចំណាត់ការនេះ ឬមិនលើសពី 10 ថ្ងៃក្រោយពីពួកយើងផ្ញើឲ្យអ្នកនូវសេចក្ដីជូនដំណឹងពីចំណាត់ការនេះ បើអ្នកទទួលបានផលប្រយោជន៍ឥឡូវនេះ ហើយអ្នកចង់ឲ្យវានៅតែបន្ត ឬ
- ក្នុងរយៈពេល 90 ថ្ងៃពីកាលបរិច្ឆេទដែលអ្នកទទួលបានលិខិតនេះ ។

នៅសវនាការ អ្នកមានសិទ្ធិតំណាងខ្លួនឯង ត្រូវបានតំណាងដោយមេធាវី ឬដោយបុគ្គលផ្សេងទៀតដែលអ្នកជ្រើសរើស ។ អ្នកអាចទទួលបានយោបល់ផ្នែកច្បាប់ ឬការតំណាងដោយឥតគិតថ្លៃ ដោយទាក់ទងការិយាល័យសេវាកម្មច្បាប់ ។

ការរាយការណ៍ពីការផ្លាស់ប្ដូរទូរស័ព្ទ

ទូរស័ព្ទ 1-877-501-2233 ឬទូរសារ 1-888-338-7410

លើបណ្ដាញទៅ ៖ Washingtonconnection.org

សំបុត្រ ៖ DSHS Customer Service Contact Center
P.O. Box 11699
Tacoma WA 98411
បញ្ចូលលេខសម្គាល់អតិថិជនរបស់អ្នកលើទំព័រនីមួយៗដែលអ្នកបញ្ជូនមក ។